**ព្រះរាជាណាចក្រកម្ពុជា**

**ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**បទអន្តរាគមន៍របស់**

**ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) លើកទី១**

**ស្តីពី**

# សិទ្ធិប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច : គោលនយោបាយ និងលទ្ធផលសំរេចបាន

( ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ )

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ជារៀងរហូតមក រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ចំពោះសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ជាពិសេស ចំពោះសិទ្ធិរបស់ពួកគាត់ទាក់ទងនឹងការប្រើប្រាស់ដីធ្លី និងការទាញយកអនុផលព្រៃឈើ តាមទំលាប់ប្រពៃណី ដូចដែលពួកគាត់ធ្លាប់អនុវត្តកន្លងមក ។ ស្មារតីនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈច្បាប់ជាច្រើន មានជាអាទិ៍ រដ្ឋធម្មនុញ្ញ (១៩៩៣) ច្បាប់ភូមិបាល (២០០១) ច្បាប់ព្រៃឈើ (២០០២) ។ ឯកសារបឋមនៃក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី (២០០២) របស់រាជរដ្ឋាភិបាលក៏បានបញ្ជាក់ច្បាស់នូវស្មារតីនេះ ។

ដើម្បីធ្វើឱ្យស្មារតីនេះក្លាយទៅជាការពិតជាក់ស្តែង រាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាគោលនយោបាយដីធ្លី បាននិងកំពុងរៀបចំគោលនយោបាយ ស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព ។ ក្នុងពេលជាមួយគ្នានេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ក៏បាននិងកំពុងរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍តំបន់ជនជាតិដើមភាគតិចផងដែរ ។

ការរៀបចំតាក់តែងឯកសារគោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានផ្តួចផ្តើមឡើងនាឆ្នាំ ២០០៣ ដោយមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីជាអ្នកសំរបសំរួល និងដោយមានការគាំទ្រជំនួយបច្ចេកទេសពីអង្គការ GTZ ។

នាឆ្នាំ ២០០៤ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតក្រុមការងារចំរុះថ្នាក់ជាតិមួយ ដែលមានសមាសភាពមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងមានក្រុមការងារថ្នាក់ខេត្ត ដើម្បីសិក្សាសាកល្បងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ ក្រុមការងារនេះបានធ្វើការសិក្សាស្រាវជ្រាវ ដោយឈរលើមូលដ្ឋាននៃឯកសារជាច្រើន ពិសេសឯកសារដែលបានស្រាវជ្រាវ ដោយមានកិច្ចសហការរួមគ្នារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងអ្នកជំនាញការនៃអង្គការ GTZ ។

ក្នុងឆ្នាំ ២០០៥ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានបន្តធ្វើការពិភាក្សាជាមួយក្រុមការងារចំរុះថ្នាក់ជាតិ និងថ្នាក់ខេត្ត និងធ្វើការកែលំអសេចក្តីព្រាងគោលនយោបាយជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងពីបរិបទ និងវប្បធម៌ប្រពៃណី ទំនៀមទំលាប់របស់ជនជាតិដើមភាគតិច។

ឯកកសារសេចក្តីព្រាងគោលនយោបាយនេះ ត្រូវបានដាក់ឱ្យពិគ្រោះយោបល់ជាសាធារណៈយ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធ និងជនជាតិដើមភាគតិចនៅតាមបណ្តាខេត្តដែលរួមមានៈ

១. **ការពិគ្រោះយោបល់ជាមួយឥស្សរជននយោបាយជាន់ខ្ពស់ជនជាតិដើមភាគតិច** ដែលជាសមាជិកព្រឹទ្ធសភា រដ្ឋសភា និងជាថ្នាក់ដឹកនាំខេត្ត នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦។

២. **សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ :** នៅខេត្តរតនគិរី នាថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០៦ ដោយមានការចូលរួមពីតំណាងសហគមន៍ជនជាតិដើមភាគតិចមកពី ខេត្តរតនគិរី ព្រះវិហារ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងមន្ត្រីបង្គោលមកពីក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលព្រៃឈើ) ព្រមទាំងតំណាងសង្គមស៊ីវិលមួយចំនួន ដែលមានអ្នកចូលរួមសរុបចំនួន ១៨៦ នាក់។

៣. **សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ :** នៅភ្នំពេញ នាថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៧ ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចំនួន ១៤ និងមានតំណាងជនជាតិដើមភាគតិច មកពីខេត្តព្រះវិហារ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ស្ពឺ និងពោធិសាត់ ។ក្រៅពីនេះក៏មានការចូលរួមពីតំណាងអង្គការជាតិ អន្តរជាតិ និងសង្គមស៊ីវិលជាច្រើនទៀត ដែលមានអ្នកចូលរួមសរុប ចំនួន ១៦០ នាក់។

ផ្អែកលើមតិយោបល់ដែលទទួលបានពីសិក្ខាសាលាពិគ្រោះយោបល់ទាំងនេះ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានធ្វើការកែសំរួលដោយសហការជាមួយក្រុមការងារចំរុះថ្នាក់ជាតិម្តងទៀត ហើយបានដាក់ឆ្លងសម័យប្រជុំក្រុមប្រឹក្សាគោលនយោបាយដីធ្លី កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧ ប្រកបដោយលទ្ធផលវិជ្ជមាន។

សេចក្តីព្រាងគោលនយោបាយនេះត្រូវបានផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧ ដើម្បីពិនិត្យ និងអនុម័ត ។ គួរកត់សំគាល់ថា សេចក្តីព្រាងគោលនយោបាយនេះមានភាពរលូនទៅនឹងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍តំបន់ជនជាតិដើមភាគតិច។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ចំពោះមុខនេះ ដើម្បីការពារជាបណ្តោះអាសន្ននូវសិទ្ធិប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងសហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋនៃខេត្តពាក់ព័ន្ធ ដើម្បីណែនាំអនុវត្តវិធានការបណ្តោះអាសន្ន ដើម្បីការពារដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈគំរោងសាកល្បងចំនួន៣កន្លែង នៅខេត្តរតនគីរី ក្នុងភូមិល្អឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ និងក្នុងភូមិឡាអ៊ឺន ឃុំតឺន ស្រុកកូនមុំ និងនៅខេត្តមណ្ឌលគីរី ក្នុងភូមិអណ្តូងក្រឡឹង ឃុំអូររាំង ស្រុកអូររាំង ដោយអនុវត្តតាមស្មារតីនៃអនុក្រឹត្យ លេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ។

ឆ្លៀតឱកាសនេះ ខ្ញុំសុំស្នើភាគីពាក់ព័ន្ធទាំងអស់ផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំគោលនយោបាយស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដោយចៀសវាងនូវប្រការណាដែលនាំឱ្យយឺតយ៉ាវដល់ដំណើរការនេះ។

**សូមអរគុណ !**